blue california
Promise Health Plan
601 Potrero Grande Drive
Monterey Park, CA 91755

## ក្រដាសកែតម្រូវចំពោះបញ្ជីឈ្មោះអ្នកផ្តល់សេវា និងឱសថស្ថាន BLUE SHIELD PROMISE CAL MEDICONNECT ឆ្នាំ 2022

### នេះគឺជាព័ត៌មានសំខាន់ អំពីការផ្លាស់ប្តូរចំពោះការរ៉ាប់រង Blue Shield Promise Cal MediConnect ឆ្នាំ 2022 របស់អ្នក។

កាលពីមុន យើងបានផ្តល់ឲ្យអ្នកនូវ បញ្ជីឈ្មោះអ្នកផ្តល់សេវា និងឱសថស្ថាន ឆ្នាំ 2022 ដែលផ្តល់ព័ត៌មាន អំពីការរ៉ាប់រងរបស់អ្នក ឋានៈជាសមាជិកនៃគំរោងរបស់យើង។ នេះគឺជាសេចក្តីជូនដំណឹង ថាព័ត៌មាននៅក្នុងបញ្ជីឈ្មោះអ្នកផ្តល់សេវា និងឱសថស្ថាន ឆ្នាំ 2022 ត្រូវបានកែប្រែ។ ផ្នែក B3៖ សេវា និងការគាំទ្រយូរអង្វែង (Long-Term Services and Supports, LTSS) បានផ្លាស់ប្តូរ។

នៅក្នុងផ្នែក B3 នោះ Blue Shield Promise បានយកចេញការសំអាងទៅ សេវាការគាំទ្រក្នុងផ្ទះ (In-Home Supportive Services, IHSS) និង កម្មវិធីសេវាព្រឹទ្ធាវ័យ ពហុគោលបំណង (Multipurpose Senior Services Program, MSSP) នៅទំព័រ 15 ដល់ 16។ ខាងក្រោមនេះ អ្នកនឹងរកឃើញព័ត៌មានបានកែប្រែ ដែលរៀបរាប់ការកែតម្រូវ។

### ការផ្លាស់ប្តូរចំពោះបញ្ជីឈ្មោះអ្នកផ្តល់សេវា និងឱសថស្ថាន ឆ្នាំ 2022 របស់អ្នក

ពាក្យបានយកចេញ គឺបានបង្ហាញក្នុងតារាងខាងក្រោម ដោយបន្ទាត់ឆូត។ ពាក្យបានយកចេញ មានរូបភាពយ៉ាងនេះ៖ ~~ពាក្យបានយកចេញ~~។

| បញ្ជីឈ្មោះអ្នកផ្តល់សេវា និងឱសថស្ថាន | ព័ត៌មានពីដើម | ព័ត៌មានបានកែតម្រូវ | តើការនេះមានន័យយ៉ាងណាសំរាប់អ្នក? |
|---|---|---|---|
| B3. សេវា និងការគាំទ្រយូរអង្វែង ទំព័រ 15 ដល់ 16 | ឋានៈជាមាជិកនៃ Blue Shield Promise Cal MediConnect Plan អ្នកអាចនឹងទទួល សេវា និងការគាំទ្រយូរអង្វែង (LTSS) បានដូចជា | ឋានៈជាមាជិកនៃ Blue Shield Promise Cal MediConnect Plan អ្នកអាចនឹងទទួល សេវា និងការគាំទ្រយូរអង្វែង (LTSS) បានដូចជា | អត្ថប្រយោជន៍ IHSS របស់អ្នកនឹងមិនផ្លាស់ប្តូរទេ, ការគ្រប់គ្រងនៃអត្ថប្រយោជន៍ គឺដោយក្រសួងសង្គមកិច្ច រដ្ឋ California |

| | | | |
|---|---|---|---|
| | កម្មវិធីសេវាមនុស្សពេញវ័យ ពេលថ្ងៃតាមសហគមន៍ (Community-Based Adult Day Services, CBAS) ដែលផ្តល់សេវាថែទាំជំងឺ, វិធីព្យាបាលរូបកាយ, អាជីវកម្ម និងសំដី, សកម្មភាពវិធីព្យាបាល, និងអាហារ នៅតាមមជ្ឈមណ្ឌល ក្នុងសហគមន៍។ ~~សេវាការគាំទ្រក្នុងផ្ទះ (In-Home Supportive Services, IHSS), ការថែទាំក្នុងផ្ទះ សំរាប់មនុស្សដែលមិនអាចនៅក្នុងផ្ទះរបស់គេ ដោយសុវត្ថិភាពបាន ដោយគ្មានការផ្តល់ជំនួយថែទាំ។~~ | កម្មវិធីសេវាមនុស្សពេញវ័យ ពេលថ្ងៃតាមសហគមន៍ (Community-Based Adult Day Services, CBAS) ដែលផ្តល់សេវាថែទាំជំងឺ, វិធីព្យាបាលរូបកាយ, អាជីវកម្ម និងសំដី, សកម្មភាពវិធីព្យាបាល, និងអាហារ នៅតាមមជ្ឈមណ្ឌល ក្នុងសហគមន៍។ | |
| B3. សេវា និងការគាំទ្រយូរអង្វែង ទំព័រ 15 ដល់ 16 | សេវា និងការគាំទ្រយូរអង្វែង ផ្សេងទៀត បានផ្តល់ដោយ Blue Shield Promise Cal MediConnect Plan រួមមាន ~~កម្មវិធីសេវាព្រឹទ្ធាវ័យពហុគោលបំណង (Multipurpose Senior Services Program, MSSP)។ MSSP គឺជាកម្មវិធីចាត់ចែងករណី Medicaid Waiver សំរាប់ព្រឹទ្ធាវ័យអាយុ 65 ឆ្នាំ និងចាស់ជាង ដែលមានសិទ្ធិទទួល Medi-Cal និងអាចបញ្ជាក់បាន សំរាប់ការដាក់ឲ្យនៅក្នុងមន្ទីរវេជ្ជកម្ម ប៉ុន្តែប្រាថ្នាចង់រស់នៅ ក្នុងសហគមន៍ជាដដែល។ អ្នកចាត់ចែងការថែទាំ MSSP ធ្វើការជាមួយនឹងអ្នកទទួលអត្ថប្រយោជន៍, សមាជិកគ្រួសាររបស់គេ, និងក្រុមពេទ្យ ដើម្បីសំគាល់ និងសំរបសំរួលសេវានៅក្នុងផ្ទះ;~~ ថែទាំយូរអង្វែង/ថែរក្សាបីបាច់ គឺជាការទំនុកបំរុងខាងសុខភាព, សង្គម និងសេវាថែទាំខ្លួន បានផ្តល់ឲ្យអ្នកទទួល Medi-Cal ដែលមិនអាចរស់នៅដោយសុវត្ថិភាព នៅតាមផ្ទះ ប៉ុន្តែមិនត្រូវការនៅក្នុងមន្ទីរពេទ្យ។ បុគ្គលត្រូវបានដាក់នៅ ~~តាមកម្រិតនៃការថែទាំសមរម្យបំផុត សំរាប់~~ | សេវា និងការគាំទ្រយូរអង្វែង ផ្សេងទៀត បានផ្តល់ដោយ Blue Shield Promise Cal MediConnect Plan រួមមាន ការថែទាំយូរអង្វែង (Long Term Care, LTC)/ថែរក្សាបីបាច់, ដែលជាការទំនុកបំរុងខាងសុខភាព, សង្គម និងសេវាថែទាំខ្លួន ឲ្យអ្នកទទួល Medi-Cal ដែលមិនអាចរស់នៅដោយសុវត្ថិភាព នៅតាមផ្ទះ ប៉ុន្តែមិនត្រូវការនៅក្នុងមន្ទីរពេទ្យ។<br>បុគ្គលត្រូវបានដាក់នៅក្នុង មន្ទីរវេជ្ជកម្ម (Nursing Facility, NF) ដែលសមរម្យបំផុត ដោយយោងលើសេចក្តីត្រូវការខាងសុខភាព។ ដើម្បីរកមើលអ្នកផ្តល់សេវាទាំងនេះ មើលទំព័រ 28 ក្នុងបញ្ជីឈ្មោះនេះ។ អ្នកសំរបសំរួលថែទាំរបស់អ្នក អាចប្រាប់អ្នកថែមទៀត អំពីរបៀបទទួល IHSS, MSSP និងមានសេវាផ្សេងៗទៀត ដើម្បីជួយអ្នករស់នៅ ដោយកក់ក្តៅនៅតាមផ្ទះ ឬសហគមន៍របស់អ្នក ដោយឯករាជ្យជាទីបំផុត តាមការតម្រូវសិទ្ធិទទួល, និងរបៀបដាក់ពាក្យសុំកម្មវិធីទាំងនេះ។ | អត្ថប្រយោជន៍ MSSP របស់អ្នកនឹងមិនបានផ្លាស់ប្តូរទេ។ អ្នកនឹងរក្សាការទទួល សេវានៃ MSSP របស់អ្នក មកពីទីតាំងនៃ MSSP របស់អ្នក។ ការគ្រប់គ្រងនៃអត្ថប្រយោជន៍ គឺដោយក្រសួងជន្មាយុរដ្ឋ California។ |

| | | | |
|---|---|---|---|
| | ~~សេចក្តីត្រូវការសុខភាពរបស់គេ និងរួមទាំង មន្ទីរគិលានុបដ្ឋាកម្ម មានជំនាញ (Skilled Nursing Facility,SNF), មន្ទីរថែទាំធ្ងន់ធ្ងរ ខ្លាំង, មន្ទីរថែទាំមធ្យម។~~ ដើម្បី រកមើលអ្នកផ្តល់សេវាទាំងនេះ មើលទំព័រ 28 ក្នុងបញ្ជីឈ្មោះនេះ។ | | |

អ្នកមិនបានតម្រូវឲ្យធ្វើអ្វី ដើម្បីតបឆ្លើយចំពោះឯកសារនេះទេ ប៉ុន្តែ**យើងសូមឲ្យយោបល់អ្នក រក្សាទុកព័ត៌មាននេះ សំរាប់ជាការសំអាងនៅពេល អនាគត។** បើសិនអ្នកមានសំណួរអ្វី សូមហៅមកយើង លេខ (855) 905-3825 (TTY: 711) ម៉ោង 8 ព្រឹក ដល់ 8 យប់ ប្រាំពីរថ្ងៃ មួយអាទិត្យ។

អ្នកអាចទទួលឯកសារនេះ ដោយឥតគិតថ្លៃ ជាទំរង់ផ្សេងទៀត ដូចជាអក្សរពុម្ពធំៗ អក្សរប្រ៊ោល ឬជាសំឡេង។
ហៅ (855) 905-3825 (TTY: 711) ម៉ោ   8 ព្រឹក ដល់ 8 យប់ ប្រាំពីរថ្ងៃ មួយអាទិត្យ។ ហៅគឺឥតគិតថ្លៃ។

Blue Shield Promise Cal MediConnect គឺជាគំរោងសុខភាពមួយ ដែលមានកិច្ចសន្យា ជាមួយទាំង Medicare និង Medi-Cal ដើម្បីផ្តល់អត្ថប្រយោជន៍ នៃកម្មវិធីទាំងពីរមុខ សំរាប់អ្នកចុះឈ្មោះ។